# គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

របាយការណ៍ហិរញ្ញវត្ថុ
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016
និង
របាយការណ៍របស់សវនករឯករាជ្យ

# ព័ត៌មានអំពីក្រុមហ៊ុន

| | | |
|---|---|---|
| ក្រុមហ៊ុន | **គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត** | |
| ចុះបញ្ជីពាណិជ្ជកម្មលេខ | Co. 0700 KH/2010 | |
| ទីស្នាក់ការចុះបញ្ជី | អគារលេខ 101A ផ្លូវលេខ 289 | |
| | សង្កាត់បឹងកក់ 1 ខណ្ឌទួលគោក | |
| | រាជធានីភ្នំពេញ | |
| | ព្រះរាជាណាចក្រកម្ពុជា | |
| ភាគទុនិក | លោកស្រី អ៊ូ សាន | |
| | លោកស្រី ឌិត នីតា | |
| ក្រុមប្រឹក្សាភិបាល | លោក ធន់ វឌ្ឍនា | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក ខាត់ សុខគាន | អនុប្រធានក្រុមប្រឹក្សាភិបាល |
| | លោក ខូវ សូវៀត | សមាជិក |
| អ្នកគ្រប់គ្រង | លោកស្រី ឌិត នីតា | អគ្គនាយិកាប្រតិបត្តិ |
| | លោក ខូវ មករារ័ត្ន | អគ្គនាយករងប្រតិបត្តិ |
| | លោក ទិត វណ្ណារិទ្ធ | នាយកនាយកដ្ឋានគណនេយ្យ និង ហរិញ្ញវត្ថុ |
| | លោក លី ឈាង | នាយកនាយកដ្ឋានឥណទាន |
| | លោក យ៉ាំង ហៃ | នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| | លោក មុំ ចាន់សុធា | នាយកនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស |
| ធនាគារិកចម្បង | ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ | |
| | ធនាគារ អេ អ៊ិន ហ្សេត រ៉ូយ៉ាល់ (កម្ពុជា) | |
| | ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា | |
| | ធនាគារ អេស៊ីលីដា ភីអិលស៊ី | |
| | ធនាគារ វឌ្ឍនៈ លីមីធីត | |
| | ធនាគារ កាថេយ្យូណៃធីត | |
| | ធនាគារ ហ្វីលីព ភីអិលស៊ី | |
| សវនករ | ខេភីអឹមជី ខេមបូឌា ចំកាត់ | |

# គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## មាតិកា


| | | ទំព័រ |
|---|---|---|
| 1. | របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 |
| 2. | របាយការណ៍របស់សវនករឯករាជ្យ | 6 |
| 3. | តារាងតុល្យការ | 10 |
| 4. | របាយការណ៍លទ្ធផល | 11 |
| 5. | របាយការណ៍ស្តីពីបម្រែបម្រួលមូលធន | 12 |
| 6. | របាយការណ៍លំហូរទឹកប្រាក់ | 13 |
| 7. | កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 15 |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានក្តីសោមនស្សរីករាយ ធ្វើការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និង របាយការណ៍ហិរញ្ញវត្ថុរបស់ **គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត** ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 ។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ គ្រឹះស្ថានខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុទូលំទូលាយ ប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាពទៅដល់សហគ្រិនធុនតូច និងមធ្យម ដែលជាកសិករ សិប្បករ និងអាជីវករ ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 មានដូចខាងក្រោម៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់ចំណេញមុនបង់ពន្ធ | 382,270 | 1,543,224 | 396,814 | 1,607,097 |
| ពន្ធលើប្រាក់ចំណេញ | (70,996) | (286,611) | (80,980) | (327,969) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 311,274 | 1,256,613 | 315,834 | 1,279,128 |

## ភាគលាភ

នៅថ្ងៃទី 8 ខែ សីហា ឆ្នាំ 2016 ក្រុមប្រឹក្សាភិបាលបានប្រកាស និងបានបែងចែកភាគលាភ ចំនួនទឹកប្រាក់ 160,000 ដុល្លារអាមេរិក ។

## ដើមទុន

នៅថ្ងៃទី 21 ខែ មេសា ឆ្នាំ 2015 ក្រុមប្រឹក្សាភិបាលបានអនុម័តក្នុងការបោះទុនបន្ថែមចំនួន 1,050,000 ហ៊ុន ដែលមានតម្លៃ 1,050,000 ដុល្លារអាមេរិក ។ នៅថ្ងៃទី 5 ខែ កញ្ញា ឆ្នាំ 2015 ក្រុមហ៊ុនបានទទួលការអនុម័តពីធនាគារជាតិនៃ កម្ពុជា ដើម្បីបង្កើនដើមទុនពីចំនួនទឹកប្រាក់ 1,053,000 ដុល្លារអាមេរិក ដល់ 2,103,000 ដុល្លារអាមេរិក ដោយប្រាក់ពីភាគទុនិកចំនួន 850,000 ដុល្លារអាមេរិក និងបង្វិលពីប្រាក់ចំណេញរក្សាទុក ចំនួន 200,000 ដុល្លារអាមេរិក ។

នាថ្ងៃចេញរបាយការណ៍នេះ ការកែសម្រួលលើលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនទាន់ទទួលការអនុម័ត ពីក្រសួងពាណិជ្ជកម្មនៅឡើយទេ ។


គ្រឹះស្ថានឯកជន
Private Company
ផ្ទះលេខ១០១អា ផ្លូវ២៨៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក ភ្នំពេញ
ADDRESS # 101A, ST.289, BOEUNG KAK 1, TOUL KORK, PHNOM PENH
TEL: (855) 23 996 936, 023 533 9999 WEBSITE: WWW.CAMMA.COM.KH

# គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់ឥណទានដែលបានដឹងថាមិនអាចទារបានត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ឥណទានដែលជាប់សង្ស័យ ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលនាំឲ្យឥណទានអាក្រក់ដែលបានជំរះចេញពីបញ្ជី ឬចំនួនសំវិធានធនជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្តទាំងអស់ក្រៅពីបំណុលដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ។

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ។

# គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត (ត)

ក្រុមប្រឹក្សាភិបាល មានមតិថាពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល 12 ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់ ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវនោះទេ ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាល មានមតិថា៖

(ក) លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ ។

(ខ) នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ ដល់ថ្ងៃចេញរបាយការណ៍នេះពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំពុំមានព្រឹត្តិការណ៍សារវន្តកើតឡើងក្រោយនាថ្ងៃចេញរបាយការណ៍នេះ ដែលតម្រូវឲ្យមានការលាតត្រដាង ឬនិយ័តភាពក្រៅពីព្រឹត្តិការណ៍ ដែលបានលាតត្រដាងរួចហើយនៅក្នុងកំណត់សម្គាល់ ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះរួមមាន៖

- លោក ធន់ វឌ្ឍនា ប្រធានក្រុមប្រឹក្សាភិបាល
- លោកស្រី ខាត់ សុខគាន អនុប្រធានក្រុមប្រឹក្សាភិបាល
- លោក ខូវ សូវៀត សមាជិក

# គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់ បានកាន់កាប់ដោយផ្ទាល់ទៅលើភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទនេះទេ ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងនិងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាគូភាគីមួយ ក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុន ឬសញ្ញាប័ណ្ណរបស់ក្រុមហ៊ុន ឬអង្គភាពសាជីវកម្មដទៃទៀតនោះទេ ។

ចាប់តាំងពីដើមការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធនឹងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុន ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីចង្អុលបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំ របាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព ។

(ខ) អនុវត្តទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពត្រឹមត្រូវ គឺត្រូវបង្ហាញ ពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព ។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយ ដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

## គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ (ត)

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេច ដែលមានសារៈសំខាន់ទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំសូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញនៅទំព័រទី 10 ដល់ទី 50 បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ **គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត** នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

*ចុះហត្ថលេខាដោយយោងទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល:*

| | |
|---|---|
| **លោក ធន់ វឌ្ឍនា** | **លោកស្រី ឌិត នីតា** |
| *ប្រធានក្រុមប្រឹក្សាភិបាល* | *អគ្គនាយិកាប្រតិបត្តិ* |

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី: 28 APR 2017

គ្រឹះស្ថានឯកជន
Private Company
ផ្ទះលេខ១០១អា ផ្លូវ២៨៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក ភ្នំពេញ
ADDRESS # 101A, ST.289, BOEUNG KAK 1, TOUL KORK, PHNOM PENH
TEL: (855) 23 996 936, 023 533 9999 WEBSITE: WWW.CAMMA.COM.KH

KPMG Cambodia Ltd
4th Floor, Delano Center
No. 144, Street 169, Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia
+855 23 216 899 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យ
## ជូនចំពោះភាគទុនិក
## គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

### មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត** ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានតារាងតុល្យការនាថ្ងៃទី31 ខែ ធ្នូ ឆ្នាំ 2016 របាយការណ៍លទ្ធផល របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សំគាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀតដែលបានបង្ហាញនៅទំព័រទី 10 ដល់ទី 50 (ហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ") ។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី31 ខែ ធ្នូ ឆ្នាំ 2016 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

### មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដែលមាននូវក្នុងរបាយការណ៍របស់យើងខ្ញុំ ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុន ដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌វិជ្ជាជីវៈស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

KPMG Cambodia Ltd, a Cambodian limited liability company and a member firm of the KPMG network of independent member firms affiliated with KPMG International Cooperative ("KPMG International"), a Swiss entity.
Document classification: KPMG Confidential.

KPMG

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី 1 ដល់ទី 5 ។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុងឆ្គងជាសារវន្ត ។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង ។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។

ចំពោះអ្នកទទួលខុសត្រូវលើអភិបាលកិច្ច គឺត្រូវទទួលខុសត្រូវលើការត្រួតពិនិត្យដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករ ដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាអាចរកឃើញ នូវកាបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ កាបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

KPMG

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម ។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយ ចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ។

- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។

- ការវាយតម្លៃលើភាពសមស្របនៃ គោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង ។

- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃ ការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់សារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពអាជីវកម្ម ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។ យ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម ។

- វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ ។

KPMG

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀត វិសាលភាព និងពេលវេលា ដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀត ដែលមានរួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**

**ខៃ ហ៊ុយ**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 28 ខែ មេសា ឆ្នាំ 2017

# គ្រឹះស្ថាន ខេមា គ្រូហិរញ្ញវត្ថុ លីមីតធីត

## តារាងតុល្យការ
## នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016

| | កំណត់សំគាល់ | 2016 ដុល្លារអាមេរិក | 2016 ពាន់រៀល (កំណត់សំគាល់ 4) | 2015 ដុល្លារអាមេរិក | 2015 ពាន់រៀល (កំណត់សំគាល់ 4) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 5 | 82,936 | 334,813 | 47,375 | 191,869 |
| សមតុល្យនៅធនាគារ | 6 | 21,072 | 85,068 | 351,075 | 1,421,854 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 7 | 105,570 | 426,186 | 105,434 | 427,008 |
| ឥណទានផ្តល់ដល់អតិថិជនសុទ្ធ | 8 | 7,385,295 | 29,814,436 | 5,913,596 | 23,950,064 |
| ទ្រព្យសកម្មផ្សេងៗ | 9 | 120,612 | 486,910 | 101,563 | 411,330 |
| ទ្រព្យនិងបរិក្ខារ | 10 | 62,515 | 252,374 | 32,923 | 133,338 |
| ទ្រព្យសកម្មអរូបី | 11 | 48 | 194 | 867 | 3,511 |
| ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ | 13 | 6,738 | 27,200 | - | - |
| **សរុបទ្រព្យសកម្ម** | | 7,784,786 | 31,427,181 | 6,552,833 | 26,538,974 |
| **បំណុលនិងមូលធន** | | | | | |
| បំណុល | | | | | |
| បំណុលផ្សេងៗ | 12 | 94,799 | 382,704 | 64,321 | 260,500 |
| ពន្ធលើប្រាក់ចំណេញ | 13 | 63,623 | 256,846 | 68,617 | 277,899 |
| ប្រាក់កម្ចី | 14 | 5,023,472 | 20,279,756 | 3,968,277 | 16,071,522 |
| សរុបបំណុល | | 5,181,894 | 20,919,306 | 4,101,215 | 16,609,921 |
| មូលធន | | | | | |
| ដើមទុន | 15 | 2,103,000 | 8,489,811 | 2,103,000 | 8,517,150 |
| ប្រាក់ចំណេញរក្សាទុក | | 499,892 | 2,018,064 | 348,618 | 1,411,903 |
| សរុបមូលធន | | 2,602,892 | 10,507,875 | 2,451,618 | 9,929,053 |
| **សរុបបំណុលនិងមូលធន** | | 7,784,786 | 31,427,181 | 6,552,833 | 26,538,974 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍លទ្ធផល
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016

| | កំណត់សំគាល់ | 2016 ដុល្លារអាមេរិក | 2016 ពាន់រៀល (កំណត់សំគាល់ 4) | 2015 ដុល្លារអាមេរិក | 2015 ពាន់រៀល (កំណត់សំគាល់ 4) |
|---|---|---|---|---|---|
| ចំណូលពីការប្រាក់ | 16 | 1,354,914 | 5,469,788 | 1,107,366 | 4,484,832 |
| ចំណាយការប្រាក់ | 17 | (392,032) | (1,582,633) | (358,967) | (1,453,816) |
| **ចំណូលពីការប្រាក់សុទ្ធ** | | 962,882 | 3,887,155 | 748,399 | 3,031,016 |
| សំវិធានធនសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ | 8 | (47,021) | (189,824) | (28,612) | (115,879) |
| **ចំណូលការប្រាក់បន្ទាប់ពីសំវិធានធនសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ** | | 915,861 | 3,697,331 | 719,787 | 2,915,137 |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | 18 | 92,697 | 374,218 | 76,760 | 310,878 |
| ចំណាយលើបុគ្គលិក | 19 | (365,633) | (1,476,060) | (217,304) | (880,081) |
| ចំណាយរំលស់ | | (38,586) | (155,772) | (24,662) | (99,881) |
| ចំណាយទូទៅនិងរដ្ឋបាល | 20 | (222,069) | (896,493) | (157,767) | (638,956) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 382,270 | 1,543,224 | 396,814 | 1,607,097 |
| ពន្ធលើប្រាក់ចំណេញ | 13 | (70,996) | (286,611) | (80,980) | (327,969) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 311,274 | 1,256,613 | 315,834 | 1,279,128 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# គ្រឹះស្ថានខេមាមីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016

| | ដើមទុន ដុល្លារអាមេរិក | ប្រាក់ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|
| សមតុល្យនាថ្ងៃទី 1 ខែ មករា ឆ្នាំ 2015 | 1,053,000 | 232,784 | 1,285,784 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | 315,834 | 315,834 |
| ការបង្វែរប្រាក់ចំណេញរក្សាទុកទៅជាដើមទុន | 200,000 | (200,000) | - |
| ការបង្កើនដើមទុន | 850,000 | - | 850,000 |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2015 | 2,103,000 | 348,618 | 2,451,618 |
| (សមមូលពាន់រៀល - កំណត់សំគាល់ 4) | 8,517,150 | 1,411,903 | 9,929,053 |
| សមតុល្យនាថ្ងៃទី 1 ខែ មករា ឆ្នាំ 2016 | 2,103,000 | 348,618 | 2,451,618 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | 311,274 | 311,274 |
| ភាគលាភបានបង់សម្រាប់ការិយបរិច្ឆេទ | - | (160,000) | (160,000) |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 | 2,103,000 | 499,892 | 2,602,892 |
| (សមមូលពាន់រៀល - កំណត់សំគាល់ 4) | 8,489,811 | 2,018,064 | 10,507,875 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍លំហូរទឹកប្រាក់
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016

| | កំណត់សំគាល់ | 2016<br>ដុល្លារអាមេរិក | 2016<br>ពាន់រៀល<br>(កំណត់សំគាល់ 4) | 2015<br>ដុល្លារអាមេរិក | 2015<br>ពាន់រៀល<br>(កំណត់សំគាល់ 4) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | | 311,274 | 1,256,613 | 315,834 | 1,279,128 |
| និយ័តភាពលើ: | | | | | |
| រំលស់ | | 38,586 | 155,772 | 24,662 | 99,881 |
| សំវិធានធនសម្រាប់ ឥណទានអាក្រក់ និងសង្ស័យ | | 47,021 | 189,824 | 28,612 | 115,879 |
| ចំណូលការប្រាក់សុទ្ធ | | (962,882) | (3,887,155) | (748,399) | (3,031,016) |
| ចំណាយពន្ធលើប្រាក់ចំណេញ | | 70,996 | 286,611 | 80,980 | 327,969 |
| | | (495,005) | (1,998,335) | (298,311) | (1,208,159) |
| ប្រែប្រួលនៃ: | | | | | |
| ឥណទានផ្តល់ដល់អតិថិជន | | (1,518,720) | (6,131,073) | (1,217,248) | (4,929,854) |
| ទ្រព្យសកម្មផ្សេងៗ | | (7,340) | (29,632) | (6,992) | (28,318) |
| បំណុលផ្សេងៗ | | 22,320 | 90,106 | 1,560 | 6,318 |
| សាច់ប្រាក់ប្រើក្នុងប្រតិបត្តិការ | | (1,998,745) | (8,068,934) | (1,520,991) | (6,160,013) |
| ពន្ធលើប្រាក់ចំណេញបានបង់ | | (82,728) | (333,973) | (61,938) | (250,849) |
| ការប្រាក់បានទទួល | | 1,343,205 | 5,422,519 | 1,097,037 | 4,443,000 |
| ការប្រាក់បានបង់ | | (383,875) | (1,549,703) | (363,850) | (1,473,593) |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ | | (1,122,143) | (4,530,091) | (849,742) | (3,441,455) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | | - | - | (52,500) | (212,625) |
| ប្រាក់បញ្ញើមានកាលកំណត់ | | 200,000 | 807,400 | (200,000) | (810,000) |
| ការទិញទ្រព្យ និងបរិក្ខារ | | (67,359) | (271,928) | (12,597) | (51,018) |
| សាច់ប្រាក់សុទ្ធទទួលបានពី/(ប្រើក្នុង) សកម្មភាពវិនិយោគ | | 132,641 | 535,472 | (265,097) | (1,073,643) |

# គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍លំហូរទឹកប្រាក់ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016

| | កំណត់សំគាល់ | 2016 ដុល្លារអាមេរិក | 2016 ពាន់រៀល (កំណត់សំគាល់ 4) | 2015 ដុល្លារអាមេរិក | 2015 ពាន់រៀល (កំណត់សំគាល់ 4) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | 7,016,208 | 28,324,431 | 5,871,800 | 23,780,790 |
| ការទូទាត់សងប្រាក់កម្ចី | | (5,961,012) | (24,064,605) | (5,559,887) | (22,517,542) |
| សាច់ប្រាក់ទទួលបានពីការបង្កើនដើមទុន | | - | - | 850,000 | 3,442,500 |
| ភាគលាភបានបង់ | | (160,000) | (645,920) | - | - |
| សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពហិរញ្ញប្បទាន | | 895,196 | 3,613,906 | 1,161,913 | 4,705,748 |
| **ការ(ថយចុះ)/កើនឡើងនៃសាច់ប្រាក់ និង សាច់ប្រាក់សមមូលសុទ្ធ** | | (94,306) | (380,713) | 47,074 | 190,650 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ | | 198,734 | 804,873 | 151,660 | 618,015 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (2,584) | - | (3,792) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** | | 104,428 | 421,576 | 198,734 | 804,873 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលមាន:** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 5 | 82,936 | 334,813 | 47,375 | 191,869 |
| សមតុល្យធនាគារនានា | 6 | 21,072 | 85,068 | 151,075 | 611,854 |
| ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា | 7 | 420 | 1,695 | 284 | 1,150 |
| | | 104,428 | 421,576 | 198,734 | 804,873 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016

### 1. អំពីក្រុមហ៊ុន

គ្រឹះស្ថាន ខេមា មី ក្រូហិរញ្ញវត្ថុ លីមីតធីត (“ក្រុមហ៊ុន”) បានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្រោមការចុះបញ្ជីពាណិជ្ជកម្មលេខ Co. 0700 KH/2010 នៅថ្ងៃទី 6 ខែ មេសា ឆ្នាំ 2010 ។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការមីក្រូហិរញ្ញវត្ថុនៅថ្ងៃទី 29 ខែ កក្កដា ឆ្នាំ 2010 ។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាមីក្រូហិរញ្ញវត្ថុទូលំទូលាយប្រកបដោយនិរន្តភាព និងប្រសិទ្ធភាពទៅដល់សហគ្រិនធុនតូចនិងមធ្យមដែលជាកសិករ សិប្បករ និងអាជីវករ ។

ការិយាល័យកណ្តាលរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅអាគារលេខ 101A ផ្លូវលេខ 289 សង្កាត់ បឹងកក់ 1 ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

គិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 ក្រុមហ៊ុនមានបុគ្គលិកចំនួន 79 នាក់ (ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2015 មានចំនួន 54 នាក់) ។

### 2. មូលដ្ឋាននៃការរៀបចំ

#### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងផ្តល់សិទ្ធិផ្សាយនៅថ្ងៃទី 28 ខែ មេសា ឆ្នាំ 2017 ។

#### (ខ) មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើមដំបូង ។

#### (គ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើរូបិយប័ណ្ណចំនួនពីរ គឺប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ។ អ្នកគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងារ និងប្រាក់រៀលជារូបិយប័ណ្ណបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីភាពចាំបាច់នៃសេដ្ឋកិច្ច នៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន ។

## 2. មូលដ្ឋាននៃការរៀបចំ (ត)

### (គ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ (ត)

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។ សមតុល្យនៃទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុនាកាលបរិច្ឆេទរាយការណ៍ ដែលជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិកក៏ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រានាកាលបរិច្ឆេទនោះ ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណដែលកើតមកពីការប្តូរនោះ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

### (ឃ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តម្រូវឲ្យអ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត ដែល មានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែលើការប៉ាន់ស្មានគណនេយ្យ ត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងការិយបរិច្ឆេទដែលការប៉ាន់ស្មាននោះ ត្រូវបានកែប្រែ និងការិយបរិច្ឆេទអនាគតដែលប៉ះពាល់ដោយការកែប្រែនេះ ។

ការប៉ាន់ស្មាន និងការវិនិច្ឆ័យគណនេយ្យចម្បងៗ ដែលបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ រួមមានការប៉ាន់ស្មាននូវចំនួនដែលអាចប្រមូលបានមកវិញពីឥណទាន និងបុរេប្រទាន ដែលបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកក្នុងកំណត់សំគាល់ទី 3 (ច) ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗខាងក្រោមនេះ ត្រូវបានអនុវត្តដោយក្រុមហ៊ុនក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ។ គោលនយោបាយទាំងអស់នេះ ត្រូវបានយកមកអនុវត្តប្រកបដោយសង្គតិភាពនៅគ្រប់ការិយបរិច្ឆេទ លើកលែងតែមានការបញ្ជាក់បន្ថែម ។

### (ក) ឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមាន សាច់ប្រាក់ និងសាច់ប្រាក់សមមូល ឥណទានផ្តល់ដល់អតិថិជន ប្រាក់បញ្ញើ គណនីត្រូវទទួលផ្សេងៗ ប្រាក់កម្ចី និងគណនីត្រូវទូទាត់ផ្សេងៗ ។ គោលនយោបាយគណនេយ្យលើការទទួលស្គាល់ និងការវាយតម្លៃនូវសមាសធាតុទាំងនេះត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកពីគ្នា ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ខ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសមតុល្យសាច់ប្រាក់ និងធនាគារ និងប្រាក់បញ្ញើនៅធនាគារនានា ដែលមានកាលវសានក្តនៅពេលតម្កល់ដំបូងមានរយៈពេល 3 ខែ ឬតិចជាង និងការវិនិយោគរយៈពេលខ្លី ដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ។

### (គ) ប្រាក់តម្កល់នៅធនាគារនានា

ប្រាក់តម្កល់នៅធនាគារនានា ត្រូវបានកត់ត្រាតាមតម្លៃដើម ដកសំវិធានធនសម្រាប់ចំនួនដែលមិនអាចប្រមូលមកវិញ ។

### (ឃ) ប្រាក់បញ្ញើតម្កល់តាមច្បាប់

ប្រាក់បញ្ញើតម្កល់តាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជាស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមាដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ។

### (ង) ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជនដែលបានបង្ហាញនៅក្នុងតារាងតុល្យការ ត្រូវបានកត់ត្រាតាមថ្លៃដើមដែលនៅសល់ ដោយដកចេញចំនួនទាំងឡាយណាដែលបានលុបចោលសំវិធានធនជាក់លាក់ និងសំវិធានធនទូទៅ ។

ឥណទានត្រូវបានលុបចោល ដោយស្វ័យប្រវត្តិ នៅពេលអតិថិជន ស្លាប់ និងក្នុងករណីណាក៏ដោយឥណទានដែលនៅសល់ មិនបានសងតាមការវាយតម្លៃរបស់អ្នកគ្រប់គ្រង និងត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល ក្នុងករណីមិនអាចប្រមូលបាន ។ ឥណទានដែលបានលុបបំបាត់ចោល ត្រូវបានកាត់ចេញពីឥណទានដែលនៅសល់ និងសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ ។

### (ច) សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ

ដើម្បីអនុវត្តទៅតាមការណែនាំរបស់ធនាគារជាតិនៃកម្ពុជា សំវិធានធនជាក់លាក់លើឥណទានអាក្រក់ និងជាប់សង្ស័យ ត្រូវបានធ្វើឡើងលើឥណទានដែលបានចាត់ទុកថាមិនដំណើរការ ហើយត្រូវបានធ្វើឡើងដូចខាងក្រោម៖

## គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ច) សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ (ត)

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| *ឥណទានរយៈពេលខ្លី (តិចជាងមួយឆ្នាំ):* | | |
| ឥណទានក្រោមស្តង់ដារ | 30 ថ្ងៃ-59 ថ្ងៃ | 10% |
| ឥណទានជាប់សង្ស័យ | 60 ថ្ងៃ-89 ថ្ងៃ | 30% |
| ឥណទានបាត់បង់ | 90 ថ្ងៃ ឬលើស | 100% |
| *ឥណទានរយៈពេលវែង (លើសពីមួយឆ្នាំ):* | | |
| ឥណទានក្រោមស្តង់ដារ | 30 ថ្ងៃ-179 ថ្ងៃ | 10% |
| ឥណទានជាប់សង្ស័យ | 180 ថ្ងៃ-359 ថ្ងៃ | 30% |
| ឥណទានបាត់បង់ | 360 ថ្ងៃ ឬលើស | 100% |

សំវិធានធននឹងត្រូវធ្វើការគណនាតាមភាគរយ នៃចំនួនសមតុល្យដែលនៅសល់ នៅពេលដែលឥណទាននោះត្រូវបានចាត់ថ្នាក់ថាមិនដំណើរការ លើកលែងតែការប្រាក់បង្គរ ។ សំវិធានធនត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន និងត្រូវទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលរៀងរាល់ខែ នៅពេលឥណទានត្រូវបានចាត់ថ្នាក់ក្រោមកម្រិតស្តង់ដារ។

ភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ ត្រូវបានវាយតម្លៃដោយអ្នកគ្រប់គ្រងរាល់ខែ ។ លក្ខខណ្ឌទាំងឡាយដែលត្រូវបានពិចារណាក្នុងការវាយតម្លៃលើភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យមានដូចជា ទំហំឥណទាន បទពិសោធន៍នៃការខាតបង់កន្លងមក លក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ន និងផលប៉ះពាល់ផ្សេងៗដល់អតិថិជន ស្ថានភាពហិរញ្ញវត្ថុអតិថិជន និងស្ថានភាពជាក់ស្តែងនៃឥណទានធៀបនឹងលក្ខខណ្ឌដែលចែងក្នុងកិច្ចសន្យា ។

ការប្រមូលមកវិញនូវឥណទាន និងបុរេប្រទានដែលបានលុបបំបាត់ចោល និងការបញ្ចូលមកវិញនូវសំវិធានធនពីមុន ត្រូវបានបង្ហាញជាចំណូលផ្សេងៗនៅក្នុងរបាយការណ៍លទ្ធផល ។

### (ឆ) ការប្រាក់ព្យួរទុក

ការប្រាក់ព្យួរទុកសំដៅលើការប្រាក់ទទួលបានពីឥណទានមិនដំណើរការ ដែលបានកត់ត្រាជាសំវិធានធន ។ វាមិនត្រូវបានកត់ត្រាជាចំណូលនោះទេលុះត្រាវាអាចប្រមូលបានមកវិញជាសាច់ប្រាក់សុទ្ធ ។

ការប្រាក់ព្យួរទុក ត្រូវបានបង្ហាញ ដោយការដកចេញគណនីការប្រាក់បង្គរ ។

# គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

#### (ជ) ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃដើម ។ ការប៉ាន់ស្មានត្រូវបានធ្វើឡើងសម្រាប់ទ្រព្យសកម្មផ្សេងៗដែលជាប់សង្ស័យ ដោយផ្អែកតាមការត្រួតពិនិត្យចំនួនដែលនៅសល់នាកាលបរិច្ឆេទរាយការណ៍ ។

#### (ឈ) ទ្រព្យ និងបរិក្ខារ

(i) ផ្នែកនៃទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរប្រសិនបើមាន ។ នៅពេលដែលធាតុរបស់ទ្រព្យ និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសៗគ្នាធាតុទាំងនោះត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នា នៃសមាសធាតុចម្បងៗរបស់ទ្រព្យ និងបរិក្ខារ ។

(ii) រំលស់លើទ្រព្យ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍លទ្ធផលលើមូលដ្ឋានរំលស់ថេរតាមយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យ និងបរិក្ខារនីមួយៗតាមអត្រា មានដូចខាងក្រោម៖

| | |
|---|---|
| ការកែលំអលើអគារ | 25% |
| គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ | 25% |
| កុំព្យូទ័រ និងបរិក្ខារបច្ចេកវិទ្យា | 25% ដល់ 50% |
| យានយន្ត | 25% |

(iii) ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុនលើសពីស្តង់ដារដើម ។ រាល់ការចំណាយបន្ទាប់ផ្សេងទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង ។

(iv) ចំណេញ ឬខាតពីការឈប់ប្រើ ឬការលក់ចេញផ្នែកនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលនាថ្ងៃឈប់ប្រើ ឬលក់ចេញ ។

(v) ទ្រព្យ និងបរិក្ខារ ដែលបានដករំលស់អស់ហើយត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ថ្ងៃដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ចេញ ឬលុបបំបាត់ចោល ។

## គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ញ) ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានកុំព្យូទ័រសូហ្វវែរ ត្រូវបានកំណត់ដោយតម្លៃដើមដករំលស់បង្គរ និង ឱនភាពនៃតម្លៃបង្គរប្រសិនបើមាន ។ ការទិញកុំព្យូទ័រសូហ្វវែរត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានទិញនិងនាំយកសូហ្វវែរនោះមកប្រើប្រាស់ ។ ទ្រព្យសកម្មអរូបី ត្រូវបានដករំលស់ដោយប្រើវិធីសាស្ត្រមូលដ្ឋានសមតុល្យថយចុះតាមអត្រា 50 % ។

### (ដ) ឱនភាពនៃតម្លៃ

### *(i) ទ្រព្យសកម្មហិរញ្ញវត្ថុ*

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃនាកាលបរិច្ឆេទរបាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានភស្តុតាងណាមួយដែលបង្ហាញថា ទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះមានឱនភាពនៃតម្លៃ ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ ប្រសិនបើមានហេតុការណ៍មួយ ឬច្រើនជះឥទ្ធិពលជាអវិជ្ជមាន លើលំហូរទឹកប្រាក់ប៉ាន់ស្មាននាពេលអនាគតដល់ទ្រព្យសកម្មនោះ ។ ករណីនេះមិនត្រូវបានប្រើសម្រាប់ឥណទានផ្ដល់ដល់អតិថិជននោះទេ ដោយវាត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែក នៅក្នុងកំណត់សំគាល់ 3 (ច) ។

រាល់ទ្រព្យសកម្មហិរញ្ញវត្ថុ សារវន្ត ត្រូវបានត្រួតពិនិត្យឱនភាពនៃតម្លៃតាមមូលដ្ឋានទោល ។ ទ្រព្យសកម្មនៅសល់ ត្រូវបានវាយតម្លៃជារួមក្នុងក្រុមទ្រព្យសកម្មដែលមាននិភ័យឥណទានស្រដៀងគ្នា ។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវដកចេញ ប្រសិនបើមានព្រឹត្តិការណ៍កើតឡើងបន្ទាប់ពីការទទួលស្គាល់ការខាតបង់លើឱនភាពនៃតម្លៃ តម្រូវឲ្យដកចេញ ។

### *(ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

តម្លៃយោងនៃទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទរបាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថា ទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលបានវិញរបស់ទ្រព្យសកម្ម ត្រូវបានធ្វើឡើង ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ដ) ឱនភាពនៃតម្លៃ (ត)

#### *(ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)*

តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្របដកចំណាយដើម្បីលក់ចេញ ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់សាច់ប្រាក់រំពឹងថានឹងទទួលបាននាពេលអនាគត ត្រូវបានអប្បហារទៅតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណនៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ សម្រាប់ទ្រព្យសកម្មទាំងនោះ ។ សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមដែលអាចបង្កើតសាច់ប្រាក់បានតូចបំផុតពីការបន្តការប្រើប្រាស់ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត ហៅកាត់ថា ("ឯកតាបង្កើតសាច់ប្រាក់") ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មមួយ ឬឯកតាបង្កើតសាច់ប្រាក់ មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកបានវិញ ។ ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

### (ឋ) ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានបង្ហាញតាមតាមសមតុល្យប្រាក់ដើមដែលនៅសល់ ។

### (ឌ) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈសារវន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ដែលរំពឹងថានឹងទទួលបាននាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណនៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឍ) ការទទួលស្គាល់ប្រាក់ចំណូល និងចំណាយ

ចំណូលការប្រាក់ដែលបានពីឥណទាន ប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា និងប្រាក់កម្កល់នៅធនាគារនានា ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានបង្គរ ។ នៅពេលដែលឥណទានមួយត្រូវបានចាត់ថ្នាក់ជាឥណទានមិនដំណើរការ ការកត់ត្រាចំណូលពីការប្រាក់ត្រូវបានព្យួរទុក រហូតដល់ពេលដែលក្រុមហ៊ុនបានទទួលសាច់ប្រាក់ជាក់ស្តែង ។ ចំណូលពីការប្រាក់ត្រូវបានធ្វើការគណនា ដោយប្រើវិធីសាស្រ្តសមតុល្យថយចុះលើសមតុល្យឥណទានដែលនៅសល់ប្រចាំខែ ។

កម្រៃសេវកម្មឥណទាន ត្រូវបានគណនាដោយប្រើប្រាស់ប្រាក់ដើម និងអត្រាកម្រៃសេវាកម្ម ហើយត្រូវបានទទួលស្គាល់ជាចំណូលនៅពេលឥណទាន ត្រូវបានផ្តល់ដល់អតិថិជន ។

ចំណាយការប្រាក់ ត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ ។

### (ណ) ភតិសន្យាប្រតិបត្តិការ

ថ្លៃឈ្នួលដែលត្រូវទូទាត់លើភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្រ្តរំលស់ថេរទៅតាមថេរវេលានៃភតិសន្យា ។ ការសន្យាភតិសន្យា មិនត្រូវបានទទួលស្គាល់ជាបំណុលទេរហូតដល់ពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចត្រូវទូទាត់ ។

### (ត) ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល លើកលែងតែក្នុងករណីដែលពន្ធលើប្រាក់ចំណេញទាក់ទងទៅនឹងធាតុណាដែលបានទទួលស្គាល់ជាផ្នែកមួយនៃមូលនិធិម្ចាស់ហ៊ុន ក្នុងករណីនេះ ពន្ធលើប្រាក់ចំណេញក៏ត្រូវបានកំណត់បង្ហាញជាផ្នែកមួយនៃមូលនិធិម្ចាស់ហ៊ុនផងដែរ ។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថា ត្រូវបង់លើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍ និងនិយ័តភាពទាំងឡាយលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

ពន្ធពន្យារ ត្រូវបានកំណត់តាមវិធីសាស្រ្តតារាងតុល្យការលើភាពលម្អៀងបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ ។ ចំនួននៃពន្ធពន្យារដែលបានកំណត់នោះ គឺផ្អែកលើលក្ខណៈដែលអាចប្រើប្រាស់បាន ឬអាចកាត់កងបានដែលនឹងកើតឡើងរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល ដោយប្រើអត្រាពន្ធកំណត់នៅថ្ងៃតារាងតុល្យការ ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ត) ពន្ធលើប្រាក់ចំណេញ (ត)

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់តែក្នុងករណីអាចនឹងកើតមានឡើងនូវប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតដែល អនុញ្ញាតឲ្យប្រើប្រាស់កាត់កងជាមួយពន្ធពន្យារនោះបាន ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានកាត់បន្ថយ ក្នុងករណីមិនអាចមាននូវការប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន ។

### (ថ) សម្ព័ន្ធញាតិ

ភាគីដែលត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិ ប្រសិនបើភាគីនោះមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោល ឬមានឥទ្ធិពលខ្លាំងលើភាគីមួយទៀតក្នុងការធ្វើសេចក្តីសម្រេចហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬក្រុមហ៊ុន និងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏មានឥទ្ធិពលខ្លាំង ។ សម្ព័ន្ធញាតិអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ហើយក៏រួមបញ្ចូលនូវសមាជិកគ្រួសារជិតស្និទ្ធជាមួយនឹងរូបវន្តបុគ្គលជាសម្ព័ន្ធញាតិផងដែរ ។

